# លិខិតចំហរួម
# អង្គការសង្គមស៊ីវិលស្នើឱ្យអាជ្ញាធរ បំពេញកាតព្វកិច្ច ជួយរក្សាការពារសណ្តាប់ធ្នាប់ នៅទីលានប្រជាធិបតេយ្យក្នុងអំឡុងពេលដែលក្រុមស្ត្រីជួបជុំ និងសម្តែងមតិ ប្រារព្ធខួបលើកទី១១៥ នៃទិវានារីអន្តរជាតិ នៅថ្ងៃទី០៨ មីនា ឆ្នាំ២០២៦

យើងខ្ញុំជាអង្គការ សមាគម សហជីព និងសហព័ន្ធសហជីព ដែលធ្វើការងារផ្នែកលើកកម្ពស់សិទ្ធិមនុស្ស សិទ្ធិការងារ និងសិទ្ធិស្ត្រី ចេញលិខិតចំហរួមនេះ ក្នុងគោលបំណងស្នើឱ្យសាលារាជធានីភ្នំពេញ បំពេញកាតព្វកិច្ចស្របតាមតួនាទី ដោយអនុលោមតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៤១ ដែលចែងអំពីសិទ្ធិក្នុងការជួបជុំ និងសម្តែងមតិ រួមទាំងលិខិតូបករណ៍នានាទាក់ទងនឹងសិទ្ធិមនុស្ស ដូចជា សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយជាដើម។ ច្បាប់ស្តីពីបាតុកម្មដោយសន្តិវិធី ពុំបានតម្រូវឱ្យក្រុមដែលចង់ធ្វើការសម្តែងមតិ ស្នើសុំពីអាជ្ញាធរ ឬអាជ្ញាធរត្រូវផ្តល់ការអនុញ្ញាតនោះឡើយ ហើយក៏ពុំគួរលើកឡើងជាទូទៅ ក្នុងការបកស្រាយខ្លឹមសារ ចំពោះការប៉ះពាល់លើសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈ រហូតដល់បំបិទសិទ្ធិសេរីភាពក្នុងការជួបជុំ និងសម្តែងមតិនោះឡើយ។

ច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី ឆ្នាំ២០០៩ គឺជាលិខិតូបករណ៍សំខាន់ដែលគ្របដណ្តប់លើសិទ្ធិសេរីភាពខាងការជួបប្រជុំនៅកម្ពុជា។ ច្បាប់នេះតម្រូវឱ្យអ្នកដឹកនាំធ្វើបាតុកម្មដោយសន្តិវិធីនៅទីកន្លែងសាធារណៈត្រូវជូនដំណឹងដល់អាជ្ញាធរដែនដី រាជធានី ឬខេត្ត មានសមត្ថកិច្ចគ្រប់ទីកន្លែង យ៉ាងតិចប្រាំថ្ងៃនៃថ្ងៃធ្វើការងារមុនពេលកំណត់នៃការធ្វើបាតុកម្ម តាមរយៈលិខិតជូនដំណឹងដែលបញ្ជាក់អំពីគោលបំណងនៃការធ្វើបាតុកម្មដោយសន្តិវិធី ព្រមទាំងទីកន្លែងបាតុកម្មជាដើម (មាត្រា៥ ដល់ មាត្រា៧)។ ច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធីចែងថា អាជ្ញាធរដែនដី រាជធានីឬខេត្តមានសមត្ថកិច្ចត្រូវឆ្លើយតបជាវិជ្ជមានចំពោះលិខិតជូនដំណឹងនោះជាលាយលក្ខណ៍អក្សរ លើកលែងតែមានព័ត៌មានច្បាស់ថា ការធ្វើបាតុកម្មនោះបង្កគ្រោះថ្នាក់ណាមួយ ឬនឹងអាចប៉ះពាល់ធ្ងន់ធ្ងរដល់សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ (មាត្រា៩)។ ប្រសិនបើមានព័ត៌មានច្បាស់ថា ការធ្វើបាតុកម្មនេះនឹងអាចបង្កគ្រោះថ្នាក់ ឬនឹងអាចប៉ះពាល់ធ្ងន់ធ្ងរណាមួយ អាជ្ញាធរដែនដី រាជធានីឬខេត្តមានសមត្ថកិច្ច ត្រូវធ្វើការឆ្លើយតបដោយជូនដំណឹងជាបន្ទាន់ទៅអ្នកដែលដាក់លិខិតជូនដំណឹង ដើម្បីឱ្យពួកគេអាចមានពេលជួបជាមួយអាជ្ញាធរមូលដ្ឋាន និងអាជ្ញាធរពាក់ព័ន្ធដទៃទៀតធ្វើការពិចារណាដើម្បីពិភាក្សាគ្នាដោះស្រាយ (មាត្រា១១)។ តែក្នុងករណីនេះ រដ្ឋបាលរាជធានីភ្នំពេញពុំបានឆ្លើយតបជាវិជ្ជមាននោះឡើយដោយបញ្ជាក់ថាមាន ព័ត៌មានច្បាស់លាស់(អំពីការអាចបង្កគ្រោះថ្នាក់)។

ក្នុងករណីនេះ រដ្ឋបាលរាជធានីភ្នំពេញពុំបានបង្ហាញនូវមូលហេតុនៅពីក្រោយនៃការធ្វើសេចក្តីសម្រេចរបស់ខ្លួនដល់អ្នករៀបចំការជួបប្រជុំឡើយចំពោះចម្លើយអវិជ្ជមានតបទៅនឹងលិខិតជូនដំណឹងនោះ។ ទោះបីជាចំណុចនេះមិនមានតម្រូវដាក់លាក់នៅក្នុងសៀវភៅណែនាំការអនុវត្តច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធីក្តីនេះគឺជាចំណុចដែលនៅតែមានបញ្ហាខ្លាំង ដោយហេតុថាទុកចន្លោះប្រហោងឱ្យមានការរឹតត្បិតដែលគ្មានមូលដ្ឋានច្បាស់លាស់ ដែលអាចរំលោភធ្ងន់ធ្ងរទៅលើកាតព្វកិច្ចរបស់ប្រទេសកម្ពុជាក្រោមមាត្រា២១ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ («ក.អ.ស.ព.ន»)។

យើងខ្ញុំស្នើដល់សាលារាជធានីភ្នំពេញសូមធ្វើការសហការដោយចូលរួមរក្សាសណ្តាប់ធ្នាប់ទីសាធារណៈ នៅពេលដែលយើងខ្ញុំជាសង្គមស៊ីវិល បានព្យាយាមក្នុងការអញ្ជើញតំណាងពីស្ថាប័នពាក់ព័ន្ធ រួមមាន ក្រសួងកិច្ចការនារី ក្រសួងការងារ និងសាលារាជធានីភ្នំពេញ ក្នុងការចូលរួមស្តាប់ក្តីកង្វល់ រួមទាំងកិច្ចប្រឹងប្រែងរបស់យើងខ្ញុំក្នុងការចម្រាញ់យកតម្រូវការ និងដំណោះស្រាយជាអាទិភាពជូនរាជរដ្ឋាភិបាល។ យើងខ្ញុំ ប្រារព្ធទិវានារីអន្តរជាតិ ដែលជាថ្ងៃមួយត្រូវបានប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋានប្រារព្ធឡើងនៅទូទាំងពិភពលោក ក្នុងគោលបំណងសម្តែងមតិ ផ្ញើសារទៅភាគីពាក់ព័ន្ធ អ្នកតាក់តែងគោលនយោបាយ និងអ្នកធ្វើសេចក្តីសម្រេចចិត្ត។ យើងខ្ញុំបានជ្រើសរើសយក ប្រធានបទ «**អនុវត្តសិទ្ធិសេរីភាព ដើម្បីយុត្តិធម៌ និងសេចក្តីថ្លៃថ្នូរ សម្រាប់ស្ត្រី និងក្មេងស្រី**» ដែលគ្រោងរៀបចំឡើង នៅថ្ងៃអាទិត្យទី០៨ ខែមីនា ឆ្នាំ២០២៦ វេលាម៉ោង ៦.០០នាទី ព្រឹក ដល់ ម៉ោង១៣.០០ នាទី រសៀល នៅទីលានប្រជាធិបតេយ្យ រាជធានីភ្នំពេញ ដើម្បីជួបជុំ និងសម្តែងមតិ តាមការគ្រោងទុក។

អាស្រ័យហេតុនេះ សូមសាធារណជន អ្នកសារព័ត៌មាន អង្គការ ស្ថាប័នពាក់ព័ន្ធជាតិ និងអន្តរជាតិ ព្រមទាំងដៃគូអភិវឌ្ឍន៍ មេត្តាជ្រាបជាព័ត៌មាន និងអញ្ជើញចូលរួមជាមួយយើងខ្ញុំក្នុងការប្រារព្ធខួបលើកទី១១៥ នៃទិវានារីអន្តរជាតិ ព្រមទាំងចូលរួមសង្កេតការណ៍ក្នុងឱកាសនៃការប្រារព្ធព្រឹត្តិការណ៍ដ៏សំខាន់នេះនៅទីលានប្រជាធិបតេយ្យ តាមកាលបរិច្ឆេទ និងពេលវេលាកំណត់ខាងលើ កុំបីអាក់ខានឡើយ៕

**តំណាងក្រុមការងាររៀបចំកម្មវិធី៖**

អ្នកស្រី អ៊ូ ទេពផល្លីន ទូរស័ព្ទ៖ ០១១ ៩៨៤ ៨៨៣
កញ្ញា ឈឹម ស៊ីថរ ទូរស័ព្ទ ៖០១៥ ៩៨៤ ៨៨៣

**អង្គការ សមាគម សហជីព សហព័ន្ធសហជីព ដែលគាំទ្រលិខិតចំហរួមនេះ រួមមាន៖**

1. សហព័ន្ធសហជីពកម្មករចំណីអាហារ និងសេវាកម្ម (CFSWF)
2. សហព័ន្ធសហជីពកម្ពុជា (CATU)
3. អង្គការសមាគមជាងត្នោត (STT)
4. អង្គការសមធម៌កម្ពុជា (EC)
5. សមាគមបណ្តាញយុវជនកម្ពុជា (CYN)
6. អង្គការក្លាហាន (Klahaan)
7. មជ្ឈមណ្ឌលសម្ព័នភាពការងារ និងសិទ្ធិមនុស្ស (CENTRAL)
8. មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR)
9. អង្គការកម្មវិធីអភិវឌ្ឍន៍ធនធានយុវជន (YRDP)
10. សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (ADHOC)
11. គណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលកម្ពុជាដើម្បីអនុសញ្ញាលុបបំបាត់រាល់ទំរង់នៃការរើសអើងលើស្ត្រីភេទ (NGO-CEDAW)
12. សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (IDEA)

13. សមាគមស្រ្តីជនបទដើម្បីក្សេត្របរិស្ថាន ( RWAA )
14. អង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ ( LICADHO )
15. សហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរ នៃក្រុមហ៊ុនណាហ្គាវើលដ៏ ( LRSU )
16. សហព័ន្ធសហជីពកម្មករនិយោជិតវិស័យទេសចរណ៍កម្ពុជា ( CTWUF )
17. សហព័ន្ធសហជីពកម្មករសំណង់ និងព្រៃឈើកម្ពុជា ( BWTUC )
18. សហព័ន្ធសហជីពឯករាជ្យ( INTUFE )
19. សហព័ន្ធសហជីពសេរីឯករាជ្យ ( FUFI )
20. សហព័ន្ធសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា ( FTUWKC )
21. សហព័ន្ធសហជីពកម្ពុជាឯករាជ្យ ( CITUFED )
22. សហព័ន្ធសហជីពឥទ្ធិពលការងារ ( FULY )